ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបញ្ជូនត្រឡប់មកកម្ពុជាវិញនូវវត្ថុបុរាណខ្មែរចំនួន៧៤រូប ពីគ្រួសារលោក ឌូក្លាស ឡាចហ្វដ (Douglas Latchford)

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនជ្រាបថា វត្ថុបុរាណខ្មែរចំនួន៧៤រូប ដែលទាមទារបានពីការកាន់កាប់របស់លោក ឌូក្លាស ឡាចហ្វដ ត្រូវបានបញ្ជូនត្រឡប់មកកម្ពុជាវិញ ដោយអនុលោមតាមកិច្ចព្រមព្រៀងឆ្នាំ២០២០ រវាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និង គ្រួសារលោក ឡាចហ្វដ។

ការបញ្ជូនត្រឡប់មកវិញនូវមរតកវប្បធម៌ខ្មែរដែលមានចំនួនដ៏ច្រើននេះ គឺជាសមិទ្ធផលដ៏ធំធេងថ្មីមួយទៀត ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បន្ទាប់ពីការបញ្ជូនវត្ថុបុរាណខ្មែរសំខាន់ៗមួយចំនួនពីគ្រួសារលោក ឡាចហ្វដ កាលពីឆ្នាំ២០២១ និងឆ្នាំ២០២៣ តាមរយៈកិច្ចខិតខំប្រឹងប្រែងជាប្រចាំរបស់កម្ពុជា ដើម្បីប្រមូលមកវិញ ថែរក្សា និងស្តារឡើងវិញនូវមរតកវប្បធម៌ដូនតាសម្រាប់កូនចៅជំនាន់ក្រោយ។

វត្ថុសិល្បៈទាំងនេះមានអាយុកាលតាំងពីសម័យមុនអង្គរ រហូតដល់សម័យរុងរឿងនៃចក្រភពអង្គរ មានជាអាទិ៍ បដិមាដ៏ល្អឯកសាងពីថ្មភក់ និងលោហធាតុ ព្រមទាំងវត្ថុប្រើប្រាស់ក្នុងកិច្ចពិធីផ្សេងៗ។ ក្នុងចំណោមវត្ថុសំខាន់ៗទាំងនេះ មានបដិមាដ៏ពិចិត្រចំនួន២ សាងពីថ្មភក់នាដើមសម័យអង្គរស្ថិតក្នុងរវាង៥០ឆ្នាំដំបូងនៃសតវត្សទី៩ ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី២ ដែលលោក ឡាចហ្វដ បានអះអាងថាមានប្រភពដើមមកពីភ្នំគូលែន។ បដិមាទេពប្រុសនិងទេពស្រីទាំង២នេះ ត្រូវបានចាត់ទុកជាស្នាដៃសិល្បៈគំរូមួយ ដែលត្រូវបានសាងក្នុងដំណាក់កាលដំបូងនៃការបង្កើតចក្រភពអង្គរ ហើយជាញឹកញាប់ត្រូវបានគេហៅថា "បដិមាមួយគូ"។ ជាមួយគ្នានេះ ផ្អែកតាមភស្តុតាងនានាបញ្ជាក់ថា បដិមាទេពស្រី ជាវត្ថុបុរាណដ៏កម្រមួយនៃរចនាបថគូលែន។ ក្រៅពីនេះ មានព្រះសិរ្សព្រះព្រហ្ម សាងពីថ្មភក់ និងបដិមាយក្ស (រាក្សស) មកពីតំបន់ប្រាសាទកោះកេរ។ ព្រះសិរ្សព្រះព្រហ្មដែលមានទម្រង់ព្រះភក្ត្រស្ងប់ និងពោរពេញដោយអំណាច ដើមឡើយជាប់ជាមួយនឹងដងខ្លួនស្ថិតក្នុងប្រាសាទធំមួយ ដែលបង្ហាញពីទស្សនៈលោកធាតុ និងភាពប្រណិតនៃរចនាបថកោះកេរ។ វត្ថុពិចិត្រមួយទៀតនោះគឺបដិមាសំរិទ្ធរចនាបថបាខែង ដែលជាស្នាដៃឯកបង្ហាញពីការវិវត្តផ្នែកបដិមាសាស្ត្រនាដើមសម័យអង្គរ។

វត្ថុទាំង៧៤នេះ ពុំមែនគ្រាន់តែជាស្នាដៃសិល្បៈទេ តែជាសាក្សីរស់នៃបញ្ញាញាណនិងទេពកោសល្យរបស់បុព្វបុរស និងដួងព្រលឹងនៃអារ្យធម៌ខ្មែរ។ អស់ជាច្រើនទសវត្សរ៍កន្លងមក រតនវត្ថុជាច្រើនបានឃ្លាតចាកឆ្ងាយពីមាតុភូមិក្នុងអំឡុងពេលសង្គ្រាម និងចលាចលក្នុងប្រទេស។ ការវិលត្រឡប់មកវិញនៃរតនវត្ថុទាំងនេះ បានបញ្ជាក់យ៉ាងច្បាស់ពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការបន្តស្វែងរកយុត្តិធម៌សម្រាប់មរតកវប្បធម៌របស់ខ្លួន និងបញ្ជូនសារយ៉ាងច្បាស់ទៅកាន់សកលលោកថា ប្រជាជនកម្ពុជាបន្តរួមគ្នាជាធ្លុងមួយក្នុងការការពារថែរក្សា

សម្បត្តិវប្បធម៌ជាតិ។ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សូមបញ្ជាក់ជាថ្មីនូវកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្ជាប់ខ្ជួន ក្នុងការថែរក្សាការពារ និងលើកស្ទួយបេតិកភណ្ឌវប្បធម៌បុរាណសម្រាប់មនុស្សជំនាន់ក្រោយ និងសម្រាប់មនុស្សជាតិទាំងមូល។

ការបញ្ជូនមកវិញនូវវត្ថុដ៏ច្រើនកាន់កាប់ដោយលោក ឡាចហ្វដ នាពេលនេះ សបញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែងជាប្រចាំរបស់កម្ពុជាដោយការព្យាយាម និងទំនួលខុសត្រូវ។ កម្ពុជាសូមបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តធ្វើការដោយភាពស្មោះត្រង់ជាមួយអ្នកកាន់កាប់សមុច្ច័យឯកជន ស្ថាប័ន និងរដ្ឋាភិបាលនានាជុំវិញពិភពលោក ដើម្បីធានាថា មរតកវប្បធម៌ខ្មែរជាទីសក្ការៈត្រូវបានវិលត្រឡប់មកកាន់ប្រទេសដើមវិញ។ រាល់ការវិលត្រឡប់មកវិញនៃសម្បត្តិវប្បធម៌ជាតិ គឺមានអត្ថន័យដ៏ជ្រាលជ្រៅក្នុងការព្យាបាលរបួសផ្លូវចិត្ត និងការស្តារឡើងវិញនូវវប្បធម៌ជាតិ។

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតជូន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងជាអតីតនាយករដ្ឋមន្ត្រី និង សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និងនយោបាយឈ្នះ-ឈ្នះ ដែលបាននាំមកនូវសន្តិភាពពេញលេញ និងស្ថិរភាព ដែលបង្កើតលក្ខខណ្ឌចាំបាច់សម្រាប់ការទាមទារត្រឡប់មកវិញនូវសម្បត្តិវប្បធម៌ខ្មែរ ដែលបានរសាត់ចាកចេញពីមាតុភូមិ ក្នុងអំឡុងពេលសង្គ្រាម។

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សូមថ្លែងអំណរគុណ និងកោតសរសើរដោយស្មោះ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់សមត្ថកិច្ចអង់គ្លេស ដូចជា៖ អង្គភាពសិល្បៈនិងវត្ថុបុរាណនៃស្កុតលែនយ៉ាដ(Art & Antiques Unit of Scotland Yard), ក្រុមការងារប្រឆាំងឧក្រិដ្ឋកម្មបេតិកភណ្ឌ, អង្គភាពសន្តិសុខនិងគ្រប់គ្រងព្រំដែន (OSCE Heritage Crime Task Force, Border Security and Management Unit, Transnational Threats Department) ស្ថានទូតអង់គ្លេសនៅភ្នំពេញ និងអាជ្ញាធរពាក់ព័ន្ធទាំងនៅបរទេស និងនៅកម្ពុជា។ ជាពិសេស ក្រុមការងារបុរាណវិទ្យានិងស្រាវជ្រាវនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ចំពោះការងារប្រកបដោយវិជ្ជាជីវៈ ការព្យាយាម និងការប្រឹងប្រែងស្រាវជ្រាវ និងទាមទារយកមកវិញនូវរតនសម្បត្តិដែលមិនអាចកាត់ថ្លៃបានទាំងនេះ។

ជាចុងក្រោយ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈសូមថ្លែងអំណរគុណជាពិសេសចំពោះលោក Bradley J.Gordon នៃក្រុមហ៊ុន Edenbridge Asia ទីប្រឹក្សាផ្នែកច្បាប់របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ លោក Steven Heimberg នៃ Stalwart Law Group និងកញ្ញា Malina Antoniadis នៃ NOSTOS Stragegies ដែលបានជួយសម្របសម្រួលក្នុងដំណើរការដឹកបញ្ជូនវត្ថុទាំងនេះត្រឡប់មកកម្ពុជាវិញ និងសូមថ្លែងអំណរគុណផងដែរដល់ក្រុមហ៊ុន ជីប ម៉ុង គ្រុប, ធនាគារកាណាឌីយ៉ា, ព្រមទាំងតារាចម្រៀង លោក ងួន ចាន់ដេវីត និងលោកស្រី ទេព បូព្រឹក្ស ដែលបានចូលរួមបរិច្ចាគថវិកា ដើម្បីជួយបំពេញការចំណាយលើការដឹកជញ្ជូនត្រឡប់មកកម្ពុជាវិញនូវរតនវត្ថុនៃបេតិកភណ្ឌវប្បធម៌ខ្មែរដ៏មានតម្លៃមហាសាល។

ថ្ងៃសុក្រ ១១កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៦

| | |
|---|---|
|  | យក្ស (រាក្ស័ស)<br>ថ្មភក់<br>សម័យអង្គរ, រចនាបថកោះកេរ, ពាក់កណ្តាលទី១នៃ សតវត្សរ៍ទី១០ គ.ស.<br>កម្ពស់: ៨០ x បណ្តោយ: ៤៧ x ទទឹង: ២២ ស.ម.<br><br>**Yaksa (Rakshasa)**<br>Sandstone<br>Angkor period, Koh Ker style, 1st half of 10th C.<br>H.80 x L.47 x D.22 cm. |
|  | ព្រះស្រីអារ្យមេត្រីយ៍<br>សំលោហៈ<br>សម័យអង្គរ, រចនាបថបាខែង, ដើមសតវត្សរ៍ទី១០ គ.ស.<br>កម្ពស់: ៩៣ ស.ម.<br><br>**Maitreya**<br>Copper alloyed<br>Angkor period, Bakheng style? early 10th C.<br>H. 93 cm. |
|  | ព្រះហរិហរៈ<br>ថ្មភក់<br>សម័យមុនអង្គរ, រចនាបថកំពង់ព្រះ ? ដើមសតវត្សរ៍ ទី៨ គ.ស.<br>កម្ពស់: ១៥០ ស.ម.<br><br>**Harihara**<br>Sandstone<br>Pre-Angkor period, Kampong Preah style? early 8th C.<br>H.150 cm. |

| **រូបថត - Photograph** | **ពិពណ៌នា - Description** |
|---|---|
|  | ព្រះនារាយណ៍<br>ថ្មភក់<br>សម័យអង្គរ, រចនាបថគូលែន, ដើមសតវត្សរ៍ទី៩ គ.ស.<br>កម្ពស់: ១៧០ ស.ម.<br><br>**Vishnu**<br>Sandstone<br>Angkor period, Kulen style, early 9th C.<br>H.170 cm. |
|  | ទេពស្រី (ព្រះនាងលក្ស្មី?)<br>ថ្មភក់<br>សម័យអង្គរ, រចនាបថគូលែន, ដើមសតវត្សរ៍ទី៩ គ.ស.<br>កម្ពស់: ១៥០ ស.ម.<br><br>**Female divinity (Laksmi?)**<br>Sandstone<br>Angkor period, Kulen style, early 9th C.<br>H.150 cm. |
|  | ព្រះសិរព្រះព្រហ្ម<br>ថ្មភក់<br>សម័យអង្គរ, រចនាបថកោះកេរ, ពាក់កណ្ដាលទី១នៃ សតវត្សរ៍ទី១០ គ.ស.<br>កម្ពស់: ៣១ ស.ម.<br><br>**Head of Brahma**<br>Sandstone<br>Angkor period, Koh Ker style, 1st half of 10th C.<br>H. 31 cm. |

<table>
<tr>
<td></td>
<td>ព្រះពុទ្ធគង់សមាធិ<br>ថ្មភក់<br>សម័យមុនអង្គរ, រចនាបថភ្នំដា, សតវត្សរ៍ទី៦-៧ គ.ស.<br>កម្ពស់: ៨៥ x បណ្តោយ: ៥៤ x ទទឹង:៣០ ស.ម.<br><br>Seated Buddha in meditation<br>Sandstone<br>Pre-Angkor period, Phnom Da style, $6^{th}$ - $7^{th}$ C.<br>H.85 x L.54 x W.30 cm</td>
</tr>
<tr>
<td></td>
<td>ព្រះនារាយណ៍<br>ថ្មភក់<br>សម័យមុនអង្គរ, រចនាបថភ្នំដា, សតវត្សរ៍ទី៦-៧ គ.ស.<br>កម្ពស់: ១០៤ ស.ម.<br><br>Vishnu<br>Sandstone<br>Pre-Angkor period, Phnom Da style, $6^{th}$ - $7^{th}$ C.<br>H.104 cm.</td>
</tr>
</table>